ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្តកំពង់ស្ពឺ

សាលាក្រុងច្បារមន

លេខ...៧៨៤...ឆ.ម.ស

ច្បារមន.ថ្ងៃទី..១១..ខែ.សីហា..ឆ្នាំ២០១១

## អភិបាល នៃគណៈអភិបាលក្រុងច្បារមន

## សូមគោរពជូន

## ឯកឧត្តមអភិបាល នៃគណៈអភិបាលខេត្តកំពង់ស្ពឺ

*ជាទីគោរពដ៏ខ្ពង់ខ្ពស់ ។*

កម្មវត្ថុ : សំណើរសុំការសម្រេចលើតម្លៃសេវានីត្យានុកូលកម្មដែលចេញដោយការិយាល័យច្រកចេញ-ចូលតែមួយរបស់ក្រុង ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំមានកិត្តិយសសូមគោរពជម្រាបជូន ឯកឧត្តមមេត្តាជ្រាបថា : សេចក្តីសម្រេចលេខ ០៨២ សសរ ចុះថ្ងៃទី ០៨ ខែកក្កដា ឆ្នាំ ២០១១ របស់ឯកឧត្តមអភិបាលខេត្តកំពង់ស្ពឺ ស្តីពីការធ្វើប្រតិភូកម្មការងារលើវិស័យនីត្យានុកូលកម្មបានទទួលរួចហើយ ប៉ុន្តែមិនទាន់បានកំណត់តម្លៃសេវា ។

ហេតុនេះដើម្បីឱ្យវិស័យនេះមានតារាងតម្លៃប្រកបដោយតម្លាភាពនោះ ខ្ញុំសូមឯកឧត្តមមេត្តាពិនិត្យសម្រេចលើតម្លៃដែលបានជូនភ្ជាប់ជាមួយ ។

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើ សូមឯកឧត្តមអភិបាល នៃគណៈអភិបាលខេត្តមេត្តាពិនិត្យ សម្រេចតាមការគួរ។

សូមជូនភ្ជាប់នូវ:

-តារាងតម្លៃ ចំនួន០១ច្បាប់

សូមឯកឧត្តមមេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ អំពីខ្ញុំ ។

អភិបាលក្រុង

ហ៊ុយ_ស៊ីវឿន

លេខ: ៥១២ ស.ន.ស.ណ

បានឃើញ និងឯកភាព

កំពង់ស្ពឺ ថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០១១

អភិបាលខេត្ត

កង ហ៊ាង

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ
សាលាខេត្តកំពង់ស្ពឺ
លេខ០៤៦.សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការធ្វើប្រតិភូកម្មការងារលើវិស័យនីត្យានុកូលកម្ម
## អភិបាលខេត្តកំពង់ស្ពឺ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត ០៥០៩/៤៦៤ ចុះថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០០៩ របស់ព្រះករុណា ព្រះបាទ សម្តេច ព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ត្រាស់បង្គាប់ តែងតាំង អភិបាលនៃគណៈអភិបាលខេត្តកំពង់ស្ពឺ ។

-យោងលិខិតលេខ ៦៩៣ ស.ជ.ណ ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០១១ របស់ក្រសួងមហាផ្ទៃ ស្តីពីការធ្វើប្រតិភូកម្ម លើការងារនីត្យានុកូលកម្មលើឯកសារថតចម្លងផ្សេងៗ ទៅឱ្យក្រុងគោលដៅដែលមានការិយាល័យច្រកចេញចូលតែមួយ ។

-យោងប្រកាសលេខ ១៥០៣ ប្រ.ក ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១១ របស់ក្រសួងមហាផ្ទៃ ស្តីពីការតែងតាំង មន្ត្រីរាជការសម្រាប់គាំទ្រការអនុវត្តចំណាយប្រតិបត្តិការអាទិភាពនៃគម្រោងការិយាល័យច្រកចេញចូលតែមួយ ។

-យោងតាមការចាំបាច់របស់ខេត្ត ។

## សម្រេច

**ប្រការ ១ :** ត្រូវបានធ្វើប្រតិភូកម្មលើការងារនីត្យានុកូលកម្មលើឯកសារថតចម្លងផ្សេងៗដល់ដែនសមត្ថកិច្ច ក្រុងច្បារមនដែលមានការិយាល័យច្រកចេញចូលតែមួយនូវវិស័យ នីត្យានុកូលកម្មដូចខាងក្រោម :

១- វិញ្ញាបនប័ត្របញ្ជាក់ការសិក្សា
២- វិញ្ញាបនប័ត្របណ្តោះអាសន្នមធ្យមសិក្សាកំរិត១
៣- វិញ្ញាបនប័ត្របណ្តោះអាសន្នមធ្យមសិក្សាកំរិត២
៤- វិញ្ញាបនប័ត្របណ្តោះអាសន្នមធ្យមសិក្សាបឋមភូមិ
៥- វិញ្ញាបនប័ត្របណ្តោះអាសន្នមធ្យមសិក្សាទុតិយភូមិ
៦- វិញ្ញាបនប័ត្របញ្ចប់ការសិក្សាថ្នាក់ទី១២
៧- វិញ្ញាបនប័ត្រចុះបញ្ជីអាករលើតម្លៃបន្ថែម
៨- វិញ្ញាបនប័ត្រប្រកបអាជីវកម្ម
៩- វិញ្ញាបនប័ត្របណ្តោះអាសន្នថ្នាក់បរិញ្ញាប័ត្រ
១០- វិញ្ញាបនប័ត្រ
១១- លិខិតបញ្ជាក់លទ្ធផលនៃការប្រលង សញ្ញាប័ត្រមធ្យមសិក្សាកំរិត១
១២- សញ្ញាប័ត្រមធ្យមសិក្សាកំរិត២ ( បំពេញវិជ្ជា)
១៣- សញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ
១៤- សញ្ញាប័ត្រមធ្យមសិក្សាគរុកោសល្យ
១៥- សញ្ញាប័ត្រមធ្យមសិក្សា
១៦- សញ្ញាប័ត្រគ្រូបង្រៀនកំរិតឧត្តម
១៧- ព្រឹត្តិបត្រលទ្ធផលសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ
១៨- បរិញ្ញាប័ត្រ
១៩- បរិញ្ញាប័ត្ររង
២០- លិខិតបញ្ជាក់ការសិក្សា
២១- អត្តសញ្ញាណប័ណ្ណ
២២- សៀវភៅស្នាក់នៅ
២៣- ប័ណ្ណសំគាល់យានយន្ត
២៤- ព្រឹត្តិប័ត្រពិន្ទុ
២៥- ពាក្យសុំបញ្ជាក់សញ្ញាប័ត្រមធ្យមសិក្សាកំរិត ២ ចំណេះដឹងទូទៅ

**ប្រការ ២ ៖** មន្ត្រីដែលទទួលបន្ទុកនីត្យានុកូលកម្មមានភារកិច្ចដូចខាងក្រោម៖

- បំរើការជួរមុខ ទទួលបន្ទុកការងារនីត្យានុកូលកម្មឯកសារ
- ពិនិត្យលើសំណុំឯកសារនានា ដែលស្នើសុំធ្វើសេចក្តីបញ្ជាក់ពីរដ្ឋបាលលើឯកសារថតចម្លងនានា តាមគោលការណ៍កំណត់
- លើកយោបល់ជូនប្រធានការិយាល័យច្រកចេញចូលតែមួយអំពីកិច្ចការនានា ដែលពាក់ព័ន្ធនិងការងារនីត្យានុកូលកម្ម
- ធ្វើការទំនាក់ទំនងជាមួយមន្ទីរអង្គភាពពាក់ព័ន្ធនានា ដើម្បីស្វែងរកឯកសារមូលដ្ឋានផ្លូវច្បាប់ពាក់ព័ន្ធ និងកិច្ចការនីត្យានុកូលកម្ម
- ទំនាក់ទំនងជាមួយប្រជាពលរដ្ឋជម្រាបជូនព័ត៌មាននានា និងឆ្លើយតបទៅនឹងសំណើសំណូមពរ របស់ប្រជាពលរដ្ឋអំពីកិច្ចការដែលខ្លួនទទួលខុសត្រូវ
- រក្សាទុកនូវឯកសារនានា ដែលបានធ្វើសេចក្តីបញ្ជាក់ជូនប្រជាពលរដ្ឋរួចហើយ
- បូកសរុបធ្វើរបាយការណ៍អំពីកិច្ចការរបស់ខ្លួនជូនប្រធានការិយាល័យច្រកចេញចូលតែមួយ
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ភារកិច្ចរបស់ប្រធានការិយាល័យច្រកចេញចូលតែមួយ ។

**ប្រការ ៣ ៖** ការធ្វើប្រតិភូកម្មលើ វិស័យនីត្យានុកូលកម្ម លើឯកសារថតចម្លងផ្សេងៗរបស់ប្រជាពលរដ្ឋនេះ គឺកំណត់តែប្រជាពលរដ្ឋដែលរស់នៅក្នុងដែនសមត្ថកិច្ចរបស់ក្រុងច្បារមនប៉ុណ្ណោះ ។

**ប្រការ ៤ ៖** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីសេចក្តីសំរេចនេះត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៥ ៖** នាយករដ្ឋបាលសាលាខេត្ត ទីចាត់ការទាំង៥ចំណុះសាលាខេត្ត លោកអភិបាលក្រុងច្បារមន លោក លោកស្រី ប្រធានការិយាល័យច្រកចេញ ចូលតែ មួយ និងមន្ត្រីទទួលបន្ទុកវិស័យនីត្យានុកូលកម្ម ត្រូវប្រតិបត្តិតាមសេចក្តីសំរេចនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

កំពង់ស្ពឺ ថ្ងៃទី ០៤ ខែកក្កដា ឆ្នាំ ២០១១

**អភិបាលខេត្ត**

**កង ហ៊ាង**

**ចម្លងជូន**

- ក្រសួងមហាផ្ទៃ
  (ដើម្បីជូនជ្រាប)
- ដូចប្រការ ៣-៥
  (ដើម្បីអនុវត្ត)
- ឯកសារ-កាលប្បវត្តិ

លេខ ០០៧៥ ...

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ច្បារមន ថ្ងៃទី ២១ ខែកក្កដា ឆ្នាំ ២០១១

អភិបាលក្រុងច្បារមន

**ហ៊ុយ សុំឿន**

# តារាងតម្លៃសេវាលិខិតរដ្ឋបាលកម្ម

| ល.រ | ប្រភេទលិខិត | តម្លៃសេវាកម្មក្នុងមួយសន្លឹក(គិតជាប្រាក់រៀល) | | |
|---|---|---|---|---|
| | | សេវាប្រតិបត្តិ | តែមប្រើ | ទឹកប្រាក់សរុប |
| ១ | វិញ្ញាបនបត្របញ្ជាក់ការសិក្សា | 500 | 300 | 800 |
| ២ | វិញ្ញាបនបត្របណ្តោះអាសន្ន មធ្យមសិក្សាកំរិត១ | 500 | 300 | 800 |
| ៣ | វិញ្ញាបនបត្របណ្តោះអាសន្ន មធ្យមសិក្សាកំរិត២ | 500 | 300 | 800 |
| ៤ | វិញ្ញាបនបត្របណ្តោះអាសន្ន មធ្យមសិក្សាបឋមភូមិ | 500 | 300 | 800 |
| ៥ | វិញ្ញាបនបត្របណ្តោះអាសន្ន មធ្យមសិក្សាទុតិយភូមិ | 500 | 300 | 800 |
| ៦ | វិញ្ញាបនបត្របញ្ជាក់ការសិក្សា ថ្នាក់ទី១២ | 500 | 300 | 800 |
| ៧ | វិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែម | 700 | 300 | 1,000 |
| ៨ | វិញ្ញាបនបត្រប្រកបអាជីវកម្ម | 700 | 300 | 1,000 |
| ៩ | វិញ្ញាបនបត្របវិញ្ញាបត្របណ្តោះអាសន្ន | 700 | 300 | 1,000 |
| ១០ | លិខិតបញ្ជាក់លទ្ធផលនៃការប្រលងសញ្ញាបត្រមធ្យមសិក្សាកំរិត១ | 500 | 300 | 800 |
| ១១ | សញ្ញាបត្រមធ្យមសិក្សាកំរិត២(បំពេញវិជ្ជា) | 500 | 300 | 800 |
| ១២ | សញ្ញាបត្រមធ្យមសិក្សា ទុតិយភូមិ | 500 | 300 | 800 |
| ១៣ | សញ្ញាបត្រមធ្យមសិក្សា គរុកោសល្យ | 500 | 300 | 800 |
| ១៤ | សញ្ញាបត្រមធ្យមសិក្សា | 500 | 300 | 800 |
| ១៥ | សញ្ញាបត្រគ្រូបង្រៀនកំរិតឧត្តម | 700 | 300 | 1,000 |
| ១៦ | ព្រឹត្តិបត្រលទ្ធផល ប្រលងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ | 700 | 300 | 1,000 |
| ១៧ | សញ្ញាបត្របវិញ្ញាបត្រជាន់ខ្ពស់ | 700 | 300 | 1,000 |
| ១៨ | សញ្ញាបត្របវិញ្ញាបត្រ | 700 | 300 | 1,000 |

| | | | | |
|---|---|---|---|---|
| ១៩ | សញ្ញាបត្របរិញ្ញាបត្ររង | 700 | 300 | 1,000 |
| ២០ | លិខិតបញ្ជាក់ការសិក្សាផ្សេងៗទៀត | 700 | 300 | 1,000 |
| ២១ | អត្តសញ្ញាណប័ណ្ណ | 700 | 300 | 1,000 |
| ២២ | សៀវភៅស្នាក់នៅ | 700 | 300 | 1,000 |
| ២៣ | ប័ណ្ណសំគាល់យានយន្ត | 700 | 300 | 1,000 |
| ២៤ | ព្រឹត្តិបត្រពិន្ទុ | 700 | 300 | 1,000 |
| ២៥ | ពាក្យសុំបញ្ជាក់សញ្ញាបត្រមធ្យមសិក្សាកំរិត២ចំណេះដឹងទូទៅ | 500 | 300 | 800 |
| ២៦ | ពាក្យសុំបញ្ជាក់សញ្ញាបត្របំពេញវជ្ជាកំរិត២ | 500 | 300 | 800 |

បានឃើញ និងឯកភាព

.................................................................

កំពង់ស្ពឺ.ថ្ងៃទី១៧...ខែ សីហា..ឆ្នាំ ២០១១

**អភិបាលខេត្ត**

**កង ហ៊ាង**

ច្បារមន.ថ្ងៃទី១៦ ខែ សីហា ឆ្នាំ ២០១១

**អភិបាលក្រុងច្បារមន**

ហ៊ុយ_ស៊ីវហ៊ឿន